**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ០០៦ សហវ

រាជធានី ភ្នំពេញ, ថ្ងៃទី ១៤ ខែ[illegible]ឆ្នាំ ២០០៤

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើត និងដាក់ឱ្យដំណើរការ ទីស្នាក់ការគយនិងរដ្ឋាករថ្មី នៅ ខេត្ត កំពង់ចាម

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ លេខ ០៤/អនក្រ/បក/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦៤/អនក្រ/បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០១
- បានឃើញ ច្បាប់ស្តីពីពន្ធលើទំនិញ នាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦-០៧-១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាព របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៣លើលិខិតលេខ ៩៩៨៧ សហវ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## <u>សំរេច</u>

<u>**ប្រការ ១:**</u> បង្កើត ទីស្នាក់ការគយនិងរដ្ឋាករ ត្នោត នៅខេត្ត កំពង់ចាម ថ្នាក់ស្មើ ការិយាល័យ នៃមន្ទីរនានា ខេត្ត - ក្រុង ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ មានដូចខាងក្រោម ÷

- ទីស្នាក់ការគយ និងរដ្ឋាករ ត្នោត ក្នុងភូមិសាស្រ្ត ភូមិ អន្លង់ព្រេះ ឃុំ គក់ ស្រុក ពញាក្រែក ខេត្ត កំពង់ចាម ។
- តួ នាទី ភារកិច្ច ស្ថិតក្នុងវចនាសម្ព័ន្ធ របស់សាខាគយនិងរដ្ឋាករខេត្តកំពង់ចាម ។

**ប្រការ ២** ទីស្នាក់ការគយនិងរដ្ឋាករ មានសិទ្ធិ និងភារកិច្ចស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធ គ្រប់គ្រងទំនិញនាំចេញ នាំចូល និងប្រមូលពន្ធតាមច្បាប់ និងលិខិតបទដ្ឋាននានា ដែលរដ្ឋបានផ្តល់សិទ្ធិអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៣** ទីស្នាក់ការគយនិងរដ្ឋាករ ត្រូវមានប្រធានមួយរូបដឹកនាំ និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

- ប្រធាន ទីស្នាក់ការគយនិងរដ្ឋាករមានឋានៈ ស្មើនឹង ប្រធាន ការិយាល័យនានាជុំវិញខេត្ត- ក្រុង និងឋានៈស្មើនឹង អនុប្រធានការិយាល័យ នៅទីចាត់ការគយនិងរដ្ឋាករ ។
- អនុប្រធាន ទីស្នាក់ការគយនិងរដ្ឋាករមានឋានៈស្មើនឹង អនុប្រធានការិយាល័យនានាជុំវិញខេត្ត- ក្រុង ។

**ប្រការ ៤:** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង បណ្តាសាខាគយនិងរដ្ឋាករ ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  « ដើម្បីជូនជ្រាប »
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អភិបាលខេត្ត កំពង់ចាម
  « ដើម្បីសហការអនុវត្ត »
- ដូចប្រការ ៤ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ - ឯកសារ

គាត ឈន់